## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ៨៤ “ខ” ក្រ៧

ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

សំណុំរឿងព្រហ្មទណ្ឌលេខ:៤១៧៦

ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

ស៊ើបសួរលេខ: ២៨៣២

ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០២០

ជំនុំជម្រះលេខ: ៤៩៧១

ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

### តាមនាមប្រជារាស្ត្រខ្មែរ

### សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង៨ និង ៣០ នាទីព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

លោកអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៤១៧៦ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] បូលីកា ហៅ សេម ភេទប្រុស កើតឆ្នាំ១៩៨៩ អាយុ៣២ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពត កំរិតវប្បធម៌ថ្នាក់ទី៦ សាសនាព្រះពុទ្ធ មុខរបរស៊ីឈ្នួលបើកឡាន ទីលំនៅមុនពេលឃុំខ្លួនរស់នៅ ផ្ទះជួលលេខ ៤០ ផ្លូវC បុរីពិភពថ្មី ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប្រសើរ “រស់” ម្តាយឈ្មោះ [redacted] សុខា“រស់” ប្រពន្ធឈ្មោះ [redacted] សុចាន់ កូន២នាក់ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ៣ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

-ឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧០៤០ ”គ១”ដឃដ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដោយមាន លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២.ឈ្មោះ [redacted] វិបុល ភេទប្រុស កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៣ អាយុ២៨ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តព្រះសីហនុ កំរិតវប្បធម៌ ថ្នាក់ទី៧ សាសនាព្រះពុទ្ធ មុខរបរស៊ីឈ្នួលបើកឡាន ទីលំនៅភូមិវាលធំ ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] សុភាព “រស់”ម្តាយឈ្មោះ [redacted] ភារី “រស់” នៅ លីវ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។



Scanned with CamScanner

-ឃុំខ្លួនបណ្ដោះអាសន្ននៅមណ្ឌលអប់រំកែប្រែទី១(មប១) តាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ ៧០៣៨ "គ១" ដឃង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដោយមានកញ្ញាមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិបុល។

៣.ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ភេទស្រី កើតថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦ អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតសង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ កំរិតវប្បធម៌ ថ្នាក់ទី៩ សាសនាព្រះពុទ្ធ មុខរបរនារីបំរើការ៉ាអូខេ ទីលំនៅមុនពេលឃាត់ខ្លួនរស់នៅផ្ទះជួលលេខ៤៤ ផ្លូវC បុរីពិភពថ្មីឈូកវ៉ា១ ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សោភារិទ្ធិ "រស់" ម្ដាយឈ្មោះ [redacted] ឡាវី "រស់" ប្ដីឈ្មោះ [redacted] លីហួរ កូន ១នាក់ ជា នីតិជន ទោសពីមុន **ធ្លាប់ជាប់ពន្ធនាគារ ៧២ថ្ងៃ** ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

-ឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧០៣៨ "គ១"ដឃង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដោយមាន លោកស្រីមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធីពុទ្ធិកា។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិភ្លូផ្អែម និងផ្ទះជួលលេខ៤០ បុរីពិភពថ្មីឈូកវ៉ា១ ផ្លូវC ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០ នាទីកម្លាំងសមត្ថកិច្ចបានចុះបង្ក្រាបករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ស្ថិតនៅចំណុចផ្លូវបេតុង ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] បូលីកា ភេទប្រុស អាយុ៣២ ឆ្នាំ និងឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ២៨ឆ្នាំ ព្រមទាំងដកហូតវត្ថុតាងញៀន ក្រាមពណ៌សថ្លា ចំនួន ២កញ្ចប់ ទម្ងន់សរុប ១៩៨,២៨(មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម និងបន្តធ្វើការឃាត់ខ្លួនឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ភេទស្រី អាយុ២៤ឆ្នាំ នៅផ្ទះលេខ៤៤ បុរីឈូកវ៉ា១ ផ្លូវC ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ សមត្ថកិច្ចបានឆែកឆេរផ្ទះលេខ៤០ បុរីឈូកវ៉ា១ ផ្លូវC ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ របស់ឈ្មោះ [redacted] ធឿន បានរកឃើញក្រាមពណ៌សថ្លាចំនួន១កញ្ចប់, អាវុធខ្លីចំនួន ១ដើម, មានគ្រាប់ ១៦គ្រាប់ ,សម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន ,ជញ្ជីងអេឡិចត្រូនិចចំនួន ២គ្រឿង។ ក្រោយការសាកសួរឈ្មោះ [redacted] បូលីកា បានឆ្លើយថាខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] ធឿន ហើយយកទៅលក់បន្តឱ្យម៉ូយនៅខេត្តកំពត ចំណេញបានប្រាក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន)រៀល ចំណែកអាវុធខ្លី ១ដើម ,គ្រាប់ចំនួន ១៦គ្រាប់ គឺជារបស់ឈ្មោះ [redacted] ធឿន បានរត់គេចខ្លួនសមត្ថកិច្ច បានកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញ របាយការណ៍លេខ ២០១/០២០ កបគញ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ របស់



Scanned with CamScanner

ការិយាល័យប្រឆាំងគ្រឿងញៀន។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៩៧៧ អ.យ.ឋ ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៤៥៦០ អ.យ.ឋ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៦៨៦ “គ១”ដ.ង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **បូលីកា** បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០នាទី ស្ថិតនៅចំណុចផ្លូវបេតុង ភូមិភ្លូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សមត្ថកិច្ចបានឃាត់ខ្លួននិងឈ្មោះ [redacted] **វិបុល** ហើយបានឆែកដកហូតថ្នាំញៀនចំនួន ២កញ្ចប់ធំ ទម្ងន់សរុប **១៩៨,២៨(មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម** ជារបស់ខ្លួន ទើបសមត្ថកិច្ចបានបន្តឆែកឆេរនៅផ្ទះជួលលេខ៤០ ផ្លូវC ភូមិភ្លូផ្អែម សង្កាត់គោរកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ របស់ខ្លួនដែលស្នាក់នៅជាមួយឈ្មោះ [redacted]ធឿន ហើយបានរកឃើញកាំភ្លើងខ្លីចំនួន ១ដើម, គ្រាប់មួយចំនួន, ផងសំរាប់ច្រកគ្រឿងញៀនមួយចំនួន ,ជញ្ជីងអេឡិចត្រូនិចចំនួន ២គ្រឿង, ឧបករណ៍ប្រើប្រាស់ថ្នាំញៀនចំនួន, ថ្នាំញៀនចំនួន ១កញ្ចប់តូច។ ខ្លួន,ឈ្មោះ [redacted]ធឿន ,ដៃគូរបស់ឈ្មោះ [redacted]ធឿន និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ជាអ្នករកស៊ីលក់ថ្នាំញៀន។ ឈ្មោះ [redacted]ធឿន បានយកថ្នាំញៀនប្រគល់ឲ្យខ្លួនយកទៅឲ្យគេនៅខេត្តកំពត គេឲ្យថ្លៃឈ្នួល ៥០ដុល្លារក្នុងមួយជើង។ កន្លងមកឈ្មោះ [redacted] **រិទ្ធីពុទ្ធិកា** ធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយពួកខ្លួនរយៈពេល ១ខែ និងធ្លាប់ទិញថ្នាំញៀនពីខ្លួនផងដែរ។ ពេលសមត្ថកិច្ចចាប់ឃាត់រូបខ្លួន ឈ្មោះ [redacted] **រិទ្ធីពុទ្ធិកា** បានខលទូរស័ព្ទមកខ្លួនប្រាប់ថា ឈ្មោះ [redacted]ធឿន ចង់ជួប។ ទើបសមត្ថកិច្ចបន្តមកធ្វើការចាប់ឃាត់ខ្លួន ឈ្មោះ [redacted] **រិទ្ធីពុទ្ធិកា** បន្ថែមទៀត។

-ជនជាប់ចោទឈ្មោះ [redacted] **វិបុល** បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ២៣ និង ៣០នាទី នៅចំណុចលើផ្លូវបេតុង សមត្ថកិច្ចបានឃាត់ខ្លួននិងឈ្មោះ [redacted] **បូលីកា** ហើយបានរកឃើញថ្នាំញៀនចំនួន ២កញ្ចប់ធំរបស់ឈ្មោះ [redacted] **បូលីកា** កន្លងមកខ្លួនមិនដែលប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] **បូលីកា** ទេ។ មុនពេលកើតហេតុ ខ្លួនមកលេងសង្សានៅម្តុំផ្សារសេនជូរី ដោយពួកខ្លួនបានជួលផ្ទះសំណាក់ដេក បន្ទាប់មកឈ្មោះ [redacted] **បូលីកា** បានខលទូរស័ព្ទមកខ្លួនហើយខ្លួនបានសុំគាត់ទៅខេត្តកំពត។

-ជនជាប់ចោទឈ្មោះ [redacted] **រិទ្ធីពុទ្ធិកា** បានឆ្លើយថា ខ្លួនមានកូនខ្ចីអាយុ ៦ថ្ងៃ។ កន្លងមកខ្លួនធ្លាប់ជាប់ពន្ធនាគារនៅ ខេត្តកណ្តាល ត្រូវបានឃុំខ្លួនរយៈពេល ៧២ថ្ងៃ ពីបទ **ប្រើប្រាស់គ្រឿងញៀន**។ ខ្លួនស្គាល់ឈ្មោះ [redacted] **បូលីកា** រយៈពេលជាង ១ខែ រាប់អានជាមិត្តភក្តិធម្មតា។ ខ្លួនបានជួយរកផ្ទះជួលឲ្យមិត្តភក្តិឈ្មោះ [redacted] **បូលីកា** ហៅ **សេម** ពិតមែនប៉ុន្តែគាត់ជាអ្នកចេញលុយថ្លៃជួលខ្លួនឯង។ ខ្លួនដឹងថាឈ្មោះ [redacted] **បូលីកា** និងឈ្មោះ [redacted]ធឿន ជាដៃគូរកស៊ីលក់ថ្នាំញៀនជាមួយគ្នា ខ្លួនធ្លាប់ទិញថ្នាំញៀនពីពួកគាត់យកមកប្រើប្រាស់ផងដែរ។ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០នាទី ខ្លួន

បានខលទូរស័ព្ទទៅឈ្មោះ [redacted] បូលីកា ប្រាប់ថាឈ្មោះ [redacted] ធឿន ត្រូវការជួបក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន។ ខ្លួនបានជួលផ្ទះលេខ៤៤ រស់នៅជុំជាមួយបងប្អូន៤ នាក់ ដោយជួយគ្នាចេញថ្លៃឈ្នួលផ្ទះទាំងអស់គ្នា។

-តាមអំណានលទ្ធផលកោសលវិច័យលេខ ២៦៧៩៣/២០ ម.ព.អជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បានបញ្ជាក់ថាសំណាកជាគ្រឿងញៀនប្រភេទម្សៅក្រាមឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាកទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧៦,០១% នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុង តារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជារបស់ឈ្មោះ [redacted] បូលីកា។

-តាមអំណានលទ្ធផលកោសលវិច័យលេខ ២៦៧៩៤/២០ ម.ព.អជ.ប.គ.៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បានបញ្ជាក់ថាសំណាកជាគ្រឿងញៀនប្រភេទម្សៅក្រាមឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាកទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧៦,០១% នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុង តារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជារបស់ឈ្មោះ ធឿន។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា:** ក្រោយពីបានស្តាប់ការសួរដេញដោលរួចមកឃើញថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ដូចមានក្នុងដីកាបញ្ជូនសំណុំរឿងមកជំនុំជម្រះ និងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៦០អ.យ.ថ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ទុកនៅដដែល។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] បូលីកា បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ និងស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថាកូនក្តីខ្លួនបានឆ្លើយសារភាពគ្រប់ដំណាក់កាល មានស្មារតីភ្ញាក់រលឹកដឹងកំហុស និងសន្យាថាឈប់ប្រព្រឹត្តកែប្រែខ្លួនជាមនុស្សល្អរស់នៅក្នុងសង្គមជាតិវិញ និងម្យ៉ាងទៀតកូនក្តីខ្លួនមានកូនតូចអាយុទើបតែ ៥ឆ្នាំ ត្រូវការអ្នករកស៊ីចិញ្ចឹមមើលថែ និងផ្គត់ផ្គង់គ្រួសារ ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រាលទោសដោយក្តីអនុគ្រោះ។

-កញ្ញាមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] វិបុល បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការ និងចម្លើយសារភាពរបស់កូនក្តីខ្លួនឃើញថា ការឃាត់ខ្លួនកូនក្តីខ្លួនពុំមានភស្តុតាងជាថ្នាំញៀន, ការចាប់ឃាត់ខ្លួនកូនក្តីខ្លួនដោយសារតែកូនក្តីខ្លួនបានសុំម៉ូតូជិះទៅខេត្តកំពតជាមួយឈ្មោះ [redacted] បូលីកា ប៉ុណ្ណោះ ហើយក៏គ្មានសាក្សីណាបញ្ជាក់ថាកូនក្តីខ្លួនពាក់ព័ន្ធនិងអំពើជួញដូរថ្នាំញៀនទេ ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ និងចម្លើយសារភាពរបស់ ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ឃើញថាការឃាត់ខ្លួនជនជាប់ចោទផ្សេងទៀតមានភស្តុតាងជាថ្នាំញៀន សម្ភារៈប្រើប្រាស់ថ្នាំញៀន ប៉ុន្តែចំពោះកូនក្តីខ្លួនឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ពុំមានភស្តុតាងជាថ្នាំញៀនហើយក៏ពុំមានសាក្សីណាម្នាក់

បានឆ្លើយដាក់បន្ទុកលើកូនក្តីខ្លួនទេ ប៉ុន្តែដោយសារតែកូនក្តីខ្លួនជាអ្នកជួយយកអាសាអ្នកដទៃជួយរកផ្ទះជួលឱ្យជនជាប់ចោទដទៃទៀតរស់នៅក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងចោទប្រកាន់ពីបទ ជួញដូរថ្នាំញៀន និងម្យ៉ាងទៀតកូនក្តីខ្លួនមានកូនតូចទើបតែសម្រាល ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ។

-ជនជាប់ចោទឈ្មោះ [redacted] បូលីកា បាននិយាយសម្តីចុងក្រោយថា: សុំឱ្យតុលាការសម្រាលទោស ។

-ជនជាប់ចោទឈ្មោះ [redacted] វិបុល បាននិយាយសម្តីចុងក្រោយថា:សុំឱ្យតុលាការជួយរកយុត្តិធម៌។

-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បាននិយាយសម្តីចុងក្រោយថា:សុំឱ្យតុលាការជួយរកយុត្តិធម៌។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ។

-ក្រោយពីបាន ពិនិត្យលើឯកសារភស្តុតាងនានា។

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

១.កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០ នាទីស្ថិតនៅចំណុច ផ្លូវបេតុង ភូមិត្នោតផ្អែម និងផ្ទះជួលលេខ៤០ បុរីពិភពថ្មីឈូកវ៉ា១ ផ្លូវC ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សមត្ថកិច្ចបានចុះបង្រ្កាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយបានធ្វើការឃាត់ខ្លួនបានជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល ដកហូតថ្នាំញៀនចំនួន ២ កញ្ចប់ទម្ងន់សរុប ១៩៨,២៨(មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម សមត្ថកិច្ចបន្តនីតិវិធីមកធ្វើការឆែកនៅផ្ទះជួលផ្ទះជួលលេខ៤០ បុរីពិភពថ្មីឈូកវ៉ា១ ផ្លូវC ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដោយបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] រិទ្ធីពុទ្ធិកា និងបានរកឃើញវត្ថុតាងគ្រឿងញៀនក្រាម ពណ៌ស ចំនួន ១កញ្ចប់, អាវុធខ្លីចំនួន ១ដើម ,គ្រាប់ ១៦គ្រាប់, សម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន, ជញ្ជីងអេឡិចត្រូនិចចំនួន ២គ្រឿង។

២.ជនជាប់ចោទឈ្មោះ [redacted] បូលីកា បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០នាទី ស្ថិតនៅចំណុចផ្លូវបេតុង ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សមត្ថកិច្ចបានឃាត់ខ្លួននិងឈ្មោះ [redacted] វិបុល ហើយបានឆែកដកហូតថ្នាំញៀនចំនួន ២ កញ្ចប់ធំទម្ងន់សរុប ១៩៨,២៨(មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម ជារបស់ខ្លួន ទើបសមត្ថកិច្ចបានបន្តឆែកផ្ទះជួលលេខ៤០ ផ្លូវC ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ របស់ខ្លួនដែលស្នាក់នៅជាមួយឈ្មោះ [redacted] ធឿន ហើយបានរកឃើញ កាំភ្លើងខ្លីចំនួន ១ដើម, គ្រាប់មួយចំនួន, ថងសំរាប់ច្រកគ្រឿងញៀនមួយចំនួន ,ជញ្ជីងអេឡិចត្រូនិចចំនួន ២គ្រឿង, ឧបករណ៍ប្រើប្រាស់ថ្នាំញៀនចំនួន, ថ្នាំញៀនចំនួន ១កញ្ចប់តូច។ ខ្លួន ,ឈ្មោះ [redacted] ធឿន ,ដៃគូរបស់ឈ្មោះ [redacted] ធឿន និងម្នាក់ទៀតមិនស្គាល់ឈ្មោះ

ជាអ្នករកស៊ីលក់ថ្នាំញៀន។ ឈ្មោះ [redacted]ធឿន បានយកថ្នាំញៀនប្រគល់ឱ្យខ្លួនយកទៅឱ្យគេនៅខេត្តកំពតគេឱ្យថ្លៃឈ្នួល ៥០ដុល្លារក្នុងមួយជើង។ កន្លងមកឈ្មោះ[redacted] វិទ្ធីពុទ្ធិកា ធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយពួកខ្លួនរយៈពេល ១ខែ និងធ្លាប់ទិញថ្នាំញៀនពីខ្លួនផងដែរ។ ពេលសមត្ថកិច្ចចាប់ឃាត់រូបខ្លួន ឈ្មោះ[redacted] វិទ្ធីពុទ្ធិកា បានខលទូរស័ព្ទមកខ្លួនប្រាប់ថា ឈ្មោះ[redacted]ធឿន ចង់ជួប។ ទើបសមត្ថកិច្ចបន្តមកធ្វើការចាប់ឃាត់ខ្លួនឈ្មោះ[redacted]វិទ្ធីពុទ្ធិកា បន្ថែមទៀត។

-តាមអំណានរបស់ចម្លើយជនជាប់ចោទឈ្មោះ[redacted] បូលីកា បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចថា ខ្លួននិងឈ្មោះ [redacted]វិបុល ជាអ្នកស្គាល់គ្នាប្រហែលជា ៥ខែធ្លាប់ធ្វើការមួយគ្នា។ កាលពីថ្ងៃកើតហេតុពួកខ្លួនកំពង់ជិះម៉ូតូបំរុងទៅខេត្តកំពត ក៏ត្រូវបានសមត្ថកិច្ចចាប់ឆែករកឃើញក្រាមពណ៌សថ្លា ចំនួន ២កញ្ចប់ ដែលខ្លួនទិញពីឈ្មោះ [redacted]ធឿន យកឱ្យឈ្មោះ ញៀន នៅខេត្តកំពត គេឱ្យចំពេញ ៥០០,០០០ (ហាសិបម៉ឺន)រៀល ក្នុងមួយលើក កន្លងមកខ្លួនធ្លាប់ដឹកថ្នាំញៀនឱ្យគេបានចំនួន ៤ដង។ សមត្ថកិច្ចបានចាប់ឃាត់ខ្លួននិងឈ្មោះ [redacted]វិបុល គេក៏អ្នកប្រើប្រាស់ថ្នាំញៀនដែរ។ ចំពោះឈ្មោះ[redacted]វិទ្ធីពុទ្ធិកា ខ្លួនធ្លាប់ស្គាល់រយៈពេល ១ខែ គាត់ជាអ្នកទិញថ្នាំញៀនពីខ្លួនប្រើប្រាស់ និងជួលផ្ទះឱ្យពួកខ្លួនស្នាក់នៅលក់គ្រឿងញៀន និងធ្លាប់ជក់ថ្នាំញៀនជា មួយគ្នាជាមួយឈ្មោះ[redacted]ធឿន ផងដែរ។ ខ្លួនបានស្នាក់នៅបន្ទប់ជាមួយឈ្មោះ ប៊ុនធឿន និងអ្នកផ្សេងទៀតមិនស្គាល់ឈ្មោះជាអ្នកជួយដូរថ្នាំញៀន។

៣.ជនជាប់ចោទឈ្មោះ [redacted] វិបុល បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០ នាទីនៅចំណុលលើផ្លូវបេតុង សមត្ថកិច្ចបានឃាត់ខ្លួននិងឈ្មោះ [redacted] បូលីកា ហើយបានរកឃើញថ្នាំញៀនចំនួន ២កញ្ចប់ធំរបស់ឈ្មោះ [redacted] បូលីកា កន្លងមកខ្លួនមិនដែលប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted]បូលីកា ទេ។ មុនពេលកើតហេតុ ខ្លួនមកលេងសង្សានៅម្តុំផ្សារសេនជូរី ដោយពួកខ្លួនបានជួលផ្ទះសំណាក់ដេក បន្ទាប់មកឈ្មោះ [redacted]បូលីកា បានខលទូរស័ព្ទមកខ្លួនហើយខ្លួនបានសុំគាត់ទៅខេត្តកំពត។

៤.ជនជាប់ចោទឈ្មោះ [redacted]វិទ្ធីពុទ្ធិកា បានឆ្លើយនាពេលសវនាការថា ខ្លួនមានកូនខ្ចីអាយុ ៦ថ្ងៃ។ កន្លងមកខ្លួនធ្លាប់ជាប់ពន្ធនាគារនៅ ខេត្តកណ្តាល ត្រូវបានឃុំខ្លួនរយៈពេល៧២ ថ្ងៃពីបទ ប្រើប្រាស់គ្រឿងញៀន។ ខ្លួនស្គាល់ឈ្មោះ [redacted] បូលីកា រយៈពេលជាង១ខែ រាប់អានជាមិត្តភក្តិធម្មតា។ ខ្លួនបានជួយរកផ្ទះជួលឱ្យមិត្តភក្តិ ឈ្មោះ [redacted] បូលីកា ហៅ សេម ពិតមែនប៉ុន្តែគាត់ជាអ្នកចេញលុយថ្លៃជួលខ្លួនឯង។ ខ្លួនដឹងថាឈ្មោះ [redacted] បូលីកា និងឈ្មោះ[redacted]ធឿន ជាដៃគូរកស៊ីលក់ថ្នាំញៀនជាមួយគ្នា ខ្លួនធ្លាប់ទិញថ្នាំញៀនពីពួកគាត់យកមកប្រើប្រាស់ផងដែរ។ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០ នាទី ខ្លួនបានខលទូរស័ព្ទទៅឈ្មោះ [redacted] បូលីកា ប្រាប់ថាឈ្មោះ [redacted]ធឿន ត្រូវការជួបក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន។ ខ្លួនបានជួលផ្ទះលេខ៤៤ រស់នៅជុំជាមួយបងប្អូន៤ នាក់ ដោយជួយគ្នាចេញថ្លៃឈ្នួលផ្ទះទាំងអស់គ្នា។

៥.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] បូលីកា និងឈ្មោះ [redacted] វិបុល ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថានៅថ្ងៃកើតហេតុសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន ឈ្មោះ [redacted] បូលីកា និងឈ្មោះ [redacted]វិបុល ព្រមទាំងដកហូតបានវត្ថុថ្នាំញៀនចំនួន ២កញ្ចប់ ទម្ងន់សរុប ១៩៨,២៨ (មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម ពីជនជាប់ចោទទាំងពីរនាក់ ដែលពួកគេបានយកទៅឱ្យម៉ូយ

នៅខេត្តកំពត។

៦.តាមចម្លើយឈ្មោះ [redacted] បូលីកា បានបញ្ជាក់ថាថ្នាំញៀនគឺឈ្មោះ [redacted] ធឿន ប្រគល់មកឱ្យខ្លួនយកទៅឱ្យម៉ូយហើយខ្លួនរស់នៅផ្ទះជាមួយឈ្មោះ [redacted] ធឿន។ ផ្ទះដែលខ្លួនស្នាក់នៅគឺឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ជាអ្នកជួយរកជួលឱ្យហើយនៅពេលសមត្ថកិច្ចចាប់រូបខ្លួន ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បានខលទូរស័ព្ទមក ទើបសមត្ថកិច្ចបានទៅធ្វើការឆែកនៅផ្ទះរបស់ខ្លួនស្នាក់នៅដកហូតបាន កាំភ្លើងខ្លីចំនួន ១ដើម, គ្រាប់មួយចំនួន , ថង់សំរាប់ច្រកគ្រឿងញៀនមួយចំនួន, ជញ្ជីងអេឡិចត្រូនិចចំនួន ២គ្រឿង ,ថ្នាំញៀនចំនួន ១កញ្ចប់តូច និងធ្វើការឃាត់ខ្លួនឈ្មោះ [redacted] រិទ្ធីពុទ្ធិកា។ ចម្លើយនេះស៊ីសង្វាក់គ្នាជាមួយឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ដែលបញ្ជាក់ថាប្តីរបស់ខ្លួនគឺឈ្មោះ [redacted] ធឿន ផ្ទះរបស់ខ្លួន និងផ្ទះរបស់ឈ្មោះ [redacted] បូលីកា ស្នាក់នៅជិតគ្នាហើយរូបខ្លួនជាអ្នកជួយរកជួលឱ្យ។ នៅថ្ងៃកើតហេតុរូបខ្លួនពិតជាបានខលទៅឈ្មោះ [redacted] បូលីកា ប្រាប់ថាឈ្មោះប៊ុនធឿន ចង់ជួបរួចខ្លួនបានបិតទូរស័ព្ទវិញ ទាំងនេះសបញ្ជាក់ឱ្យឃើញថាឈ្មោះ [redacted] ធឿន ជាប្តី ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា និងឈ្មោះ [redacted] ធឿន ដែលជាមេរបស់ឈ្មោះ [redacted] បូលីកា ជាម្ចាស់ថ្នាំញៀន គឺជាមនុស្សតែម្នាក់ រីឯឈ្មោះ [redacted] រិទ្ធីពុទ្ធិកា គឺជាអ្នកចាត់ចែងយ៉ាងសកម្មក្នុងសកម្មភាពជួញដូរថ្នាំញៀននេះ។

៧.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បូលីកា,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌មានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថាជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ពិតជាបានរកស៊ីជួញដូរថ្នាំញៀន ដើម្បីទទួលបានប្រាក់កម្រៃពិតមែន។

៨.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ដែលបានទិញថ្នាំញៀនយកមករំលែកលក់ ដើម្បីយកប្រាក់ចំណេញគឺជាអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

៩.វត្ថុតាងថ្នាំញៀនប្រភេទ ក្រាមពណ៌សថ្លា មានសារធាតុញៀនមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) ចំនួន ២កញ្ចប់ធំទម្ងន់សរុប ១៩៨,២៨(មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម ដែលដកហូតពីជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ជាភស្តុតាងស៊ីសង្វាក់ដែលអាចឱ្យតុលាការជឿបានថាជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

១០.តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២៦៧៩៣/២០ ម.ព.អជ.ប.គ.ញ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] បូលីកា ប្រភេទក្រាមម្សៅថ្លា ពណ៌សមានឈ្មោះមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ៧៦,០១% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន។ ថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] បូលីកា មានទម្ងន់ ១៩៨,២៨ក្រាម មានកម្រិតភាពសុទ្ធចំនួន $\frac{១៩៨,២៨g \times ៧៦,០១}{១០០}$ =១៥០,៧១ ក្រាម ដូច្នេះក្នុងអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១.ជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ក្នុង

ពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវអំពើរបស់ខ្លួនចំពោះមុខច្បាប់។

១២.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្តក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះ មានចេតនាទុច្ចរិតដែលការប្រព្រឹត្តនេះធ្វើឱ្យខូចនូវរបៀបរៀបរយសារធាណៈសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គម និងបំពានលើមាត្រាដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិត្នូផ្អែម និងផ្ទះជួលលេខ៤០ បុរីពិភពថ្មីឈូកវ៉ា១ ផ្លូវC ភូមិត្នូផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤.ជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ជាជនក្រីក្រគ្មាន គ្មានកំរិតវប្បធម៌ កន្លងមកជនជាប់ចោទ ៣នាក់ធ្លាប់ត្រូវបានតុលាការផ្តល់ពាក់ព័ន្ធករណីគ្រឿងញៀន គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

**១៥.វត្ថុចាប់យកមាន**

១៥.១.ថ្នាំញៀនក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីនទម្ងន់ ១៩៧,២៨ក្រាម (មួយរយកៅសិបប្រាំបីក្បៀសម្ភៃប្រាំបី)ក្រាម សល់ពីដកសំណាកធ្វើកោសលវិច័យ ដកហូតពីជនជាប់ចោទឈ្មោះ ស្វាយ បូលីកា។

១៥.២.ក្រាមពណ៌សថ្លា ចំនួន០១ កញ្ចប់តូចទម្ងន់សរុប ០,៤៩ក្រាម(សូន្យក្បៀសសែសិបប្រាំបួន)ក្រាម ដែលសល់ពីការធ្វើតេស្តពិសោធន៍បឋមរួចបានវេចខ្ចប់ដោយមានការទទួលស្គាល់និងស្នាមផ្តិតមេដៃស្តាំពីជនជាប់ចោទឈ្មោះ [redacted] ធឿន ត្រូវបានចៅក្រមស៊ើបសួរដកសំណាកយកទៅធ្វើកោសលវិច័យទាំងអស់ពុំមាននៅសល់ទេ ដូច្នេះពុំមានវត្ថុតាងថ្នាំញៀននៅសល់ដែលត្រូវឱ្យតុលាការសម្រេចរឹបអូសនោះទេ។

១៥.៣.ជញ្ជីងសំរាប់ថ្លឹងថ្នាំញៀនចំនួន ២គ្រឿង។

១៥.៤.ស្លាកលេខម៉ូតូ នគរបាល 1-6368។

១៥.៥.ឧបករណ៍ប្រើប្រាស់ថ្នាំញៀន មួយចំនួន។

ដែលបានដកហូតពីបន្ទប់ឈ្មោះ [redacted]ធឿន ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីរឹបអូសតាមបញ្ញត្តិមាត្រា៩៣ មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

១៥.៦.ប្រាក់រៀលចំនួន ២០,០០០(ពីរម៉ឺន)រៀល និងប្រាក់បាតចំនួន ៧០(ចិតសិប)បាត។

១៥.៧.នាឡិកាដៃ ចំនួន ១គ្រឿង។

ជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] វិបុល គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ។



Scanned with CamScanner

១៥.៨.ទូរស័ព្ទចំនួន ២គ្រឿង:ម៉ាក Iphone 6plus ចំនួន ១គ្រឿង និងម៉ាក Nokia ពណ៌ខ្មៅ ចំនួន ១គ្រឿង។

ជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥.៩.ទូរស័ព្ទចំនួន ១គ្រឿង: ម៉ាក VIVO ពណ៌ខៀវ។

១៥.១០.ប្រាក់រៀលចំនួន ៤០,០០០(បួនម៉ឺន)រៀល និងប្រាក់ដុល្លារចំនួន ១០(ដប់)ដុល្លារ, ប្រាក់បាតចំនួន ១២០(មួយរយម្ភៃ)បាត។

១៥.១១.កាបូបដៃចំនួន ១។

១៥.១២.ម៉ូតូចំនួន ១គ្រឿង: ម៉ាក KAVASAKI ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ 1DF-3146។

ជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] បូលីកា គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ។

១៦.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានតម្កល់បទចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ហេតុនេះគប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៧.លោកស្រីមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា សូមលោកចៅក្រមសម្រាលទោសឱ្យកូនក្តីខ្លួនឈ្មោះ [redacted] បូលីកា ដោយក្តីអនុគ្រោះ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៨.កញ្ញាមេធាវី [redacted] ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] វិបុល បានធ្វើសេចក្តីសន្និដ្ឋានថា សូមលោកចៅក្រមសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] វិបុល រួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៩.លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បានធ្វើសេចក្តីសន្និដ្ឋានថា សូមលោកចៅក្រមសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] រិទ្ធីពុទ្ធិកា រួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

២០.ជនជាប់ចោទ ឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា បានធ្វើសំណូមពរជាសំដីចុងក្រោយថាសុំឱ្យតុលាការសម្រាលទោស និងជួយរកយុត្តិធម៌ ហេតុនេះគប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

**១.ផ្តន្ទាទោស៖**

១.១.ឈ្មោះ [redacted] បូលីកា ហៅ សេម ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល។

១.២.ឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០,០០០,០០០(ម្ភៃលាន) រៀល។

១.៣.ឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិត្នោតផ្អែម និងផ្ទះជួលលេខ៤០ បុរីពិភពថ្មីឈូកវ៉ា១ ផ្លូវC ភូមិត្នោតផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពី



Scanned with CamScanner

ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុចាប់យកត្រូវរឹបអូសតាមបញ្ញត្តិមាត្រា៦២ មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា៨៣, មាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន៖

២.១.ថ្នាំញៀនក្រោមពណ៌សថ្លាប្រភេទមេតំហ្វេតាមីនទម្ងន់ ១៩៧,២៨(មួយរយកៅសិបប្រាំពីរក្បៀសម្ភៃប្រាំបី)ក្រាម សល់ពីដកសំណាកធ្វើកោសលវិច័យ។

២.២.ជញ្ជីងសំរាប់ថ្លឹងថ្នាំញៀនចំនួន ០២គ្រឿង។

២.៣.ឧបករណ៍ប្រើប្រាស់ថ្នាំញៀន មួយចំនួន។

៣.វត្ថុចាប់យកប្រគល់ឲ្យម្ចាស់ដើមវិញ មាន:

៣.១.ប្រាក់រៀលចំនួន ២០,០០០(ពីរម៉ឺន)រៀល និងប្រាក់បាតចំនួន ៧០(ចិតសិប)បាត។

៣.២.នាឡិកាដៃចំនួន ១គ្រឿង។

ប្រគល់ឲ្យឈ្មោះ [redacted] វិបុល ជាម្ចាស់ដើមវិញ។

៣.៣.ទូរស័ព្ទចំនួន ២គ្រឿង:ម៉ាក Iphone6plus ចំនួន ១គ្រឿង និងម៉ាកNokia ពណ៌ខ្មៅចំនួន ០១គ្រឿង។

ប្រគល់ឲ្យឈ្មោះ [redacted] រិទ្ធីពុទ្ធិកា ជាម្ចាស់ដើមវិញ។

៣.៤.ទូរស័ព្ទចំនួន ១គ្រឿង: ម៉ាក VIVO ពណ៌ ខៀវ។

៣.៥.ប្រាក់រៀលចំនួន ៤០,០០០(បួនម៉ឺន)រៀល និងប្រាក់ដុល្លារចំនួន ១០(ដប់)ដុល្លារ ,ប្រាក់បាតចំនួន ១២០(មួយរយម្ភៃ)បាត។

៣.៦.ការបូបដៃចំនួន ០១។

៣.៧.ម៉ូតូចំនួន ១គ្រឿង: ម៉ាក KAVASAKI ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ 1DF-3146។

ប្រគល់ឲ្យឈ្មោះ [redacted] បូលីកា ម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បូលីកា ,ឈ្មោះ [redacted] វិបុល និងឈ្មោះ [redacted] រិទ្ធីពុទ្ធិកា, ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១។ ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រា [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ១១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០២១

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner